# សភាសហភាពអឺរ៉ុបផ្តល់អនុសាសន៍ថា ប្រមុខដឹកនាំសហភាពអឺរ៉ុបនឹងផ្តល់ឋានៈបេក្ខភាពសមាជិកសហភាពអឺរ៉ុបដល់ប្រទេសអ៊ុយក្រែន



ទិដ្ឋភាពនៅខាងក្រៅសភាសហភាពអឺរ៉ុប

Kyiv Post ថ្ងៃពហស្បតិ៍ ១០កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២

សភាសហភាពអឺរ៉ុបនឹងផ្តល់អនុសាសន៍ថា ប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាលរបស់សហភាពអឺរ៉ុប ដែលគ្រោងចូលរួមប្រជុំនៅក្នុងកិច្ចប្រជុំកំពូល នាថ្ងៃទី២៣-២៤ ខែមិថុនា ឆ្នាំ២០២២ ខាងមុខនេះ នឹងផ្តល់ឋានៈបេក្ខភាពសមាជិកសហភាពអឺរ៉ុបដល់ប្រទេសអ៊ុយក្រែន និងការផ្តល់សព្វាវុធជាច្រើនទៀត តាមតម្រូវការចាំបាច់ ដែលបានបញ្ជាក់ដោយអាជ្ញាធរអ៊ុយក្រែន។

អ្នកឆ្លើយឆ្លងព័ត៌មាននៃទីភ្នាក់ងារសារព័ត៌មានរដ្ឋអ៊ុយក្រែន Ukrinform បានរាយការណ៍ថា សេចក្តីថ្លែងការណ៍ពាក់ព័ន្ធនឹងការផ្តល់ឋានៈបេក្ខភាពដល់ប្រទេសអ៊ុយក្រែននេះ ត្រូវបានធ្វើឡើងដោយលោក David McAllister ប្រធានគណៈកម្មាធិការការបរទេសនៃសភាសហភាពអឺរ៉ុបនៅក្នុងសម័យប្រជុំពេញអង្គនៃសភាសហភាពអឺរ៉ុបស្តីពី គោលនយោបាយការបរទេស សន្តិសុខ និងការពារជាតិរបស់សហភាពអឺរ៉ុប បន្ទាប់ពី ការចូលឈ្លានពានរបស់សហព័ន្ធរុស្ស៊ីក្នុងប្រទេសអ៊ុយក្រែន។

លោក McAllister បានគូសបញ្ជាក់ត្រួសៗអំពីអនុសាសន៍របស់សមាជិកសភាសហភាពអឺរ៉ុប ៨ ប្រទេស ដែលនឹងចូលរួមក្នុងកិច្ចប្រជុំកំពូលនោះ។ ប្រទេសទាំង ៨ នោះ ជាប្រទេសដែលពាក់ព័ន្ធនឹងស្ថានការណ៍ក្នុងប្រទេសអ៊ុយក្រែន។ លោក McAllister បានថ្លែងថា «យើងបានផ្តល់អនុសាសន៍ថា ប្រទេសអ៊ុយក្រែនត្រូវតែផ្តល់ឱ្យដោយមិនបង្អង់យូរឡើយ រួមទាំងអាវុធផងដែរ ទៅតាមតម្រូវការចាំបាច់ ដែលបានបញ្ជាក់ដោយអាជ្ញាធរអ៊ុយក្រែន និងត្រូវផ្តល់ឋានៈបេក្ខភាពសមាជិកសហភាពអឺរ៉ុប ខណៈពេលដែលមានសញ្ញានយោបាយច្បាស់លាស់ពីសាមគ្គីភាពជាមួយប្រជាពលរដ្ឋអ៊ុយក្រែន»។

សភាសហភាពអឺរ៉ុប ក៏បានផ្តល់អនុសាសន៍ផងដែរថា ការត្រួតពិនិត្យមើលគ្រប់ជ្រុងជ្រោយលើទណ្ឌកម្មរបស់សហភាពអឺរ៉ុប និងការអនុវត្តត្រូវបានធានា។ ការឈ្លានពានរបស់រុស្ស៊ីនៅក្នុងប្រទេសអ៊ុយក្រែន បានបង្ហាញថា សហភាពអឺរ៉ុបគួរតែផ្តល់ជាបន្ទាន់នូវមធ្យោបាយ និងគ្រឿងបរិក្ខារនានា ដើម្បីឆ្លើយតបឱ្យបានសមស្របទៅនឹងបញ្ហាសន្តិសុខស្មុគស្មាញ និងការប្រកួតប្រជែងខាងយុទ្ធសាស្ត្រជាសកល៕

*ព័ត៌មានសភាអន្តរជាតិ ០៩-០៦-២២- កែវ ជារី*

ប្រែសម្រួលពី៖ https://www.kyivpost.com/world/european-parliament-to-recommend-that-eu-leaders-grant-candidate-status-to-

https://www.kyivpost.com/world/european-parliament-to-recommend-that-eu-leaders-grant-candidate-status-to-ukraine.html

# European Parliament to recommend that EU leaders grant candidate status to Ukraine

By **UkrInform**. Published June 8 at 9:28 am

**The European Parliament will recommend that the EU Heads of State or Government, who will meet at the summit on June 23-24, 2022, grant EU candidate status to Ukraine and provide weapons in line with the needs expressed by the Ukrainian authorities.**

The relevant statement was made by Chair of the European Parliament's Committee on Foreign Affairs David McAllister at a plenary session of the European Parliament on the EU's Foreign, Security and Defence Policy after the Russian invasion of Ukraine, an Ukrinform correspondent reports.

McAllister outlined eight European Parliament's recommendations for the EU summit participants. They are related to the situation in Ukraine.

"We recommend that Ukraine be provided, without delay, with weapons in line with the needs expressed by the Ukrainian authorities and be granted EU candidate status as a clear political sign of solidarity with the people of Ukraine," McAllister said.

The European Parliament also recommended that comprehensive monitoring of EU sanctions and their implementation be ensured.

According to McAllister, the world is going through a period of geopolitical redefinition. The issues raised by Russia's war against Ukraine go far beyond the tragic situation we are currently witnessing and where Europe as a whole is challenged, McAllister noted.

Russia's aggression against Ukraine has demonstrated that the EU should be immediately provided with means and tools to respond adequately to global strategic competition and complex security issues.